# លក្ខខណ្ឌនៃគុណតម្លៃរបស់ប័ណ្ណ

## ១. សាលរង់ចាំពិសេសនៅតាមអាកាសយានដ្ឋាន

### ១.១លក្ខខណ្ឌដើម្បីទទួលបាន

- កម្មវិធីនេះគឺសម្រាប់តែម្ចាស់ប័ណ្ណដូចខាងក្រោមប៉ុណ្ណោះ:
  - ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីស៊ីវ** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
  - ប័ណ្ណឥណទាន **ប្រ៊ីដ វីសា ផ្លាទីនៀម** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
  - ប័ណ្ណឥណពន្ធ **ប្រ៊ីដ វីសា ផ្លាទីនៀម**
  - ប័ណ្ណឥណពន្ធ **ស៊ីអេសអេស ប្រ៊ីដ ព្រីមៀរ**។

### ១.២ លក្ខខណ្ឌនៃការប្រើប្រាស់ និង បទប្បញ្ញត្តិ

- អត្ថប្រយោជន៍នេះគឺសម្រាប់តែម្ចាស់ប័ណ្ណ ប្រ៊ីដ ដែលមានសិទ្ធិទទួលការផ្ដល់ជូននេះតែប៉ុណ្ណោះ **ដោយមិនអាចផ្ទេរ ឬ ផ្ដល់សិទ្ធិទៅកាន់បុគ្គលផ្សេងទៀតឡើយ។**
- ការផ្ដល់ជូននេះមិនអាចផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ ប្ដូរជាសាច់ប្រាក់ ឬ ផលិតផលផ្សេងទៀតបានទេ ព្រមទាំងមិនអាចប្រើរួមជាមួយការផ្ដល់ជូនផ្សេងៗទៀត  ឬ បញ្ចុះតម្លៃទំនិញផ្សេងទៀតបានឡើយ។

### ១.៣ សម្រាប់សេវាប្រឹក្សាយោបល់អតិថិជន

- ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម ត្រូវការជំនួយ ឬជួបប្រទះបញ្ហាណាមួយ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ

**លេខទូរសព្ទ**: ១៨០០ ២០២ ៩៩៩/ ០៩៨ ២០២ ៩៩៩
**អ៊ីម៉ែល**: info@bridgebank.com.kh
**ហ្វេសប៊ុក**: BRIDGE Bank

### ១.៤ វិសោធនកម្ម

- ធនាគារ ប្រ៊ីដ រក្សាសិទ្ធិក្នុងការផ្លាស់ប្ដូរលក្ខខណ្ឌនានាគ្រប់ពេលវេលា រួមទាំង ការកំណត់ផ្លាស់ប្ដូរប្រភេទប័ណ្ណដែលនឹងត្រូវផ្ដល់ជូន និង យន្តការគណនា ឬ ធ្វើការបញ្ចប់ការផ្ដល់ជូននេះដោយពុំមានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណ។

BRIDGE BANK

## ២. ការពិនិត្យសុខភាពប្រចាំឆ្នាំ

### ២.១ លក្ខខណ្ឌក្នុងការទទួលបាន

- អត្ថប្រយោជន៍ពិនិត្យសុខភាពប្រចាំឆ្នាំនេះ នឹងត្រូវបានផ្តល់ជូនម្ចាស់ប័ណ្ណ ប្រ៊ីដ ដោយដៃគូ សហការជាមួយរបស់ធនាគារប្រ៊ីដគឺ មជ្ឈមណ្ឌលវេជ្ជសាស្ត្រសិង្ហបុរី នៅកម្ពុជា។ ដែលនឹងត្រូវបានអនុវត្តចំពោះតែម្ចាស់ប័ណ្ណទាំងឡាយណាដែលបានបំពេញតាមលក្ខខណ្ឌរបស់កម្មវិធីតែប៉ុណ្ណោះ រួមមានប្រភេទប័ណ្ណដូចជា៖
  - ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីស៊ីវ** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
  - ប័ណ្ណឥណទាន **ប្រ៊ីដ វីសា ផ្លាទីនៀម** (ទាំងប័ណ្ណបង្គោល និង ប័ណ្ណរង)
  - ប័ណ្ណឥណពន្ធ **ប្រ៊ីដ វីសា ផ្លាទីនៀម**។

### ២.២ ការផ្តល់ជូនកញ្ចប់ពិនិត្យសុខភាព

- ម្ចាស់ប័ណ្ណឥណទាន **ប្រ៊ីដ វីសា រីស៊ីវ** មានសិទ្ធិទទួលបានការពិនិត្យសុខភាពប្រចាំឆ្នាំក្រោម 'កញ្ចប់ Comprehensive' ពី មជ្ឈមណ្ឌលវេជ្ជសាស្ត្រសិង្ហបុរី នៅកម្ពុជា ដែលផ្តល់ជូនដោយស្វ័យប្រវត្តិ។
- ម្ចាស់ប័ណ្ណឥណទាន និងឥណពន្ធ **ប្រ៊ីដ វីសា ផ្លាទីនៀម** មានសិទ្ធិទទួលបានការពិនិត្យសុខភាពប្រចាំឆ្នាំក្រោម 'កញ្ចប់ Foundation' ពី មជ្ឈមណ្ឌលវេជ្ជសាស្ត្រសិង្ហបុរី នៅកម្ពុជា នៅពេលដែលម្ចាស់ប័ណ្ណ បានចំណាយលើការទូទាត់ប្រចាំឆ្នាំចំនួន ១២,០០០.០០ ដុល្លារអាមេរិក (មួយម៉ឺនពីរពាន់ដុល្លារអាមេរិក)។

### ២.៣ លក្ខខណ្ឌនៃការប្រើប្រាស់ និង បទប្បញ្ញត្តិ

- កម្មវិធីនេះមិនអនុវត្តចំពោះបុគ្គលិកធនាគារ ប្រ៊ីដ ដែលកាន់ប័ណ្ណ **ប្រ៊ីដ វីសា ផ្លាទីនៀម** ឡើយ។
- ចំពោះកញ្ចប់ពិនិត្យសុខភាពណាមួយដែលមានតម្លៃលើសពីការផ្តល់ជូនរបស់ធនាគារ ប្រ៊ីដ មជ្ឈមណ្ឌលវេជ្ជសាស្ត្រសិង្ហបុរី រក្សាសិទ្ធិក្នុងការទូទាត់ប្រាក់ពីអតិថិជនដោយផ្ទាល់សម្រាប់សេវាកម្មទាំងនោះ។
- ការពិនិត្យសុខភាពប្រចាំឆ្នាំនេះ ត្រូវតែប្រើប្រាស់ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥។ ចំពោះអត្ថប្រយោជន៍ដែលមិនបានប្រើប្រាស់ រហូតដល់ហួសសុពលភាពនឹងត្រូវបាត់បង់សិទ្ធិក្នុងការប្រើប្រាស់ដោយស្វ័យប្រវត្តិ។
- អត្ថប្រយោជន៍នេះគឺសម្រាប់តែម្ចាស់ប័ណ្ណប៉ុណ្ណោះ ហើយមិនអាចផ្តល់ជូនចំពោះអ្នកផ្សេងបានឡើយ។

- ការផ្ដល់ជូននេះមិនអាចផ្ទេរ ឬ បូកបញ្ចូលគ្នា ឬ ប្ដូរជាសាច់ប្រាក់ ឬ ផលិតផលផ្សេងទៀតបានទេ ឬ ប្រើរួមជាមួយការផ្ដល់ជូនផ្សេងៗទៀត ឬ ប្រភេទទំនិញលក់បញ្ចុះតម្លៃ ឬ ប្រភេទទំនិញតម្លៃថេរបានឡើយ (លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ)។

### ២.៤ សម្រាប់សេវាប្រឹក្សាយោបល់អតិថិជន

- ប្រសិនបើលោកអ្នកត្រូវការព័ត៌មានបន្ថែម ត្រូវការជំនួយ ឬ ជួបប្រទះបញ្ហាណាមួយ សូមទាក់ទងមកកាន់យើងខ្ញុំតាមរយៈ

**លេខទូរសព្ទ:** ១៨០០ ២០២ ៩៩៩/ ០៩៨ ២០២ ៩៩៩
**អ៊ីម៉ែល:** info@bridgebank.com.kh
**ហ្វេសប៊ុក:** BRIDGE Bank.

### ២.៥ វិសោធនកម្ម

- ធនាគារ ប្រ៊ីដ និង មជ្ឈមណ្ឌលវេជ្ជសាស្ត្រសិង្ហបុរី រក្សាសិទ្ធិក្នុងការផ្លាស់ប្ដូរលក្ខខណ្ឌនានាគ្រប់ពេលវេលា រួមទាំង ការកំណត់ផ្លាស់ប្ដូរប្រភេទប័ណ្ណដែលនឹងត្រូវផ្ដល់ជូន និង យន្ដការគណនា ឬ ធ្វើការបញ្ចប់ការផ្ដល់ជូននេះដោយពុំមានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណ។